ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការផ្ទេរឥណទានថវិកា

***********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះ
- ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពី រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការបែងចែកឥណទានចំណាយថវិកាចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការផ្ទេរឥណទានថវិកា
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ២.៩៥០ លានរៀល ( ពីរពាន់ប្រាំបួនរយហាសិបលានរៀលគត់ ) ទៅលើសៀវភៅថវិកា របស់រដ្ឋសភា សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើត្រូវបានផ្តល់បន្ថែមទៅ ជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច ) របស់រដ្ឋសភា សំរាប់ទូទាត់ចំណាយរៀបចំសន្និសីទសមាគមសភាអាស៊ីដើម្បីសន្តិភាព ក្នុងឆ្នាំ ២០០០ ។

**មាត្រា៣:** ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០១

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ ✓

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ